# សម្រង់សារព័ត៌មានថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧

## ១.គេហទំព័រ ដើមអម្ពិល

### *កំណាយស្រាវជ្រាវ នៅអតីតមន្ទីរពេទ្យ បុរាណនាប្រាសាទទន្លេ ស្ងួតរកឃើញព្រះបដិមា«ភៃសជ្យគុរុ» ដែលជាព្រះពុទ្ធស្ដេចថ្នាំ*

អង្គារ, 08 សីហា ២០១៧ 20:41 ដោយ: ដើមអម្ពិល ID:030



ក្នុងគម្រោងស្រាវជ្រាវ ស្ដីពីមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧ ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា និងមហាវិទ្យាល័យបច្ចេកវិទ្យានិងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី បន្តប្រទះឃើញព្រះពុទ្ធបដិមាច្រើនបំណែកទៀត ក្នុងនោះ មានព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថា ជាព្រះពោធិសត្វ ដែលមានព្រះនាមហៅថា «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្ដេចថ្នាំនៅសម័យបុរាណ។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ សីហា ឆ្នាំ២០១៨ មុនបន្តជីកនិងលើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្ដៅកំណាយទី៤នៅផ្នែកខាងកើតនៃប្រាសាទទន្លស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧ផងដែរ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦សីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។

តាមលោក អ៊ឹម សុខរិទ្ធី ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្ដេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ថ ឬដៃមានដុំមូលមួយ រាងដូច សាជី។ លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧។

គួរឲ្យដឹងថា នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្ដៅកំណាយនៅផ្នែកខាងកើត ប្រាសាទ។ ក្នុងរណ្ដៅនេះដដែល ក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ។ តាមការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមានបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំនោះ។

សូមបញ្ជាក់ដែរថា គម្រោងសិក្សាស្រាវជ្រាវនៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្ដើមពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី១១ សីហា ឆ្នាំ២០១៧៕

៦.គេហទំព័រ CEN

## *កំណាយស្រាវជ្រាវ នៅអតីតមន្ទីរពេទ្យ បុរាណនាប្រាសាទទន្លេ ស្ងួតរកឃើញព្រះបដិមា«ភៃសជ្យគុរុ» ដែលជាព្រះពុទ្ធស្តេចថ្នាំ*

(ថ្ងៃទី 9 សីហា 2017, ម៉ោង 12:08:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)



សៀមរាបៈ ក្នុងគម្រោងស្រាវជ្រាវ ស្តីពីមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា និងមហាវិទ្យាល័យបច្ចេកវិទ្យានិងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី បន្តប្រទះឃើញព្រះពុទ្ធបដិមាច្រើនបំណែកទៀត ក្នុងនោះមានព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថា ជាព្រះពោធិ៍សត្វ ដែលមានព្រះនាមហៅថា «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្តេចថ្នាំនៅសម័យបុរាណ។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ សីហា ឆ្នាំ២០១៨ មុនបន្តជីកនិងលើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្តៅកំណាយទី៤នៅផ្នែកខាងកើតនៃប្រាសាទទន្លស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧ផងដែរ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦សីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។

តាមលោក អ៊ឹម សុខរិទ្ធី ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្តេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ត ឬដៃមានដុំមូលមួយ រាងដូច សាជី។ លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧។

គួរឲ្យដឹងថា នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្តៅកំណាយនៅផ្នែកខាងកើត ប្រាសាទ។ ក្នុងរណ្តៅនេះដដែល ក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ។ តាមការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមានបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំនោះ។

សូមបញ្ជាក់ដែរថា គម្រោងសិក្សាស្រាវជ្រាវនៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្តើមពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី១១ សីហា ឆ្នាំ២០១៧៕ N/S

៣.គេហទំព័រ LookingTODAY

## *កំណាយស្រាវជ្រាវ នៅអតីតមន្ទីរពេទ្យ បុរាណនាប្រាសាទទន្លេ ស្ងួតរកឃើញព្រះបដិមា«ភៃសជ្យគុរុ» ដែលជាព្រះពុទ្ធស្តេចថ្នាំ*

ថ្ងៃពុធ, 09 សីហា ២០១៧ 08:27 ដោយ: LookingTODAY Posted ID:069



សៀមរាបៈ ក្នុងគម្រោងស្រាវជ្រាវ ស្តីពីមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧ ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា និងមហាវិទ្យាល័យបច្ចេកវិទ្យានិងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី បន្តប្រទះឃើញព្រះពុទ្ធបដិមាច្រើនបំណែកទៀត ក្នុងនោះមានព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថា ជាព្រះពោធិ៍សត្វ ដែលមានព្រះនាមហៅថា «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្តេចថ្នាំនៅសម័យបុរាណ។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ សីហា ឆ្នាំ២០១៨ មុនបន្តជីកនិងលើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្តៅកំណាយទី៩នៅផ្នែកខាងកើតនៃប្រាសាទទន្លស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧ផងដែរ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦សីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។

តាមលោក អ៊ឹម សុខរិទ្ធី ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្តេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ថ ឬដៃមានដុំមូលមួយ រាងដូច សាជី។ លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧។

គួរឲ្យដឹងថា នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្តៅកំណាយនៅផ្នែកខាងកើត ប្រាសាទ។ ក្នុងរណ្តៅនេះដដែល ក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ។ តាមការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមានបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំនោះ។

សូមបញ្ជាក់ដែរថា គម្រោងសិក្សាស្រាវជ្រាវនៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្តើមពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី១១ សីហា ឆ្នាំ២០១៧៕

**៤.គេហទំព័រ** RFA

## *ក្រុមកំណាយរកឃើញបដិមាបុរាណធ្វើពីថ្មភក់ចំនួន៥ទៀតនៅប្រាសាទទន្លេស្ងួត*

ដោយ ហង្ស សារយុត 2 017-08-08 (RFA)




ក្រុមអ្នកធ្វើកំណាយជាតិ និងអន្តរជាតិ បានកំណត់ថា ប្រាសាទទន្លេស្ងួត ឬអ្នកខ្លះហៅថាប្រាសាទតុប នៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប គឺជាអតីតមន្ទីរពេទ្យបុរាណ ភាគខាងជើងរបស់សម័យអង្គរ។

ការកំណត់បែបនេះ បន្ទាប់ពីក្រុមអ្នកធ្វើកំណាយចម្រុះជាតិសាសន៍បានប្រទះឃើញរូបបដិមាធ្វើពីថ្មភក់ចំនួន៥ទៀត ដែលកប់នៅក្រោមដី ហើយក្នុងចំណោមបដិមាទាំងនោះ មានមួយអង្គគឺជារូបព្រះពុទ្ធស្តេចថ្នាំ ដែលភាសាសំស្រ្កឹតហៅថា ភៃសជ្យគុរុ (ភៃសៈជៈយៈគុរុ)។

ក្រុមអ្នកធ្វើកំណាយចម្រុះជាតិសាសន៍ដែលសហការជាមួយអ្នកជំនាញអាជ្ញាធរអប្សរា បានរកឃើញបដិមាបុរាណធ្វើពីថ្មភក់ចំនួន៥ ទៀតនៅក្នុងបរិវេណប្រាសាទទន្លេស្ងួត នៅភាគខាងជើងអង្គរធំកាលពីថ្ងៃទី៧ ខែសីហា។

មន្រ្តីមជ្ឈមណ្ឌលអន្តរជាតិ និងតម្កល់ឯកសារអង្គរ ដែលជាប្រធានការដ្ឋានកំណាយនោះ គឺលោក ខៀវ ចាន់។ លោកមានប្រសាសន៍នៅព្រឹកថ្ងៃអង្គារ ទី៨ ខែសីហា ថា ការរកឃើញរូបបដិមាបុរាណចំនួន ៥ ជាថ្មីទៀតនេះ នៅស្របពេលដែលក្រុមអ្នកជំនាញរបស់អាជ្ញាធរអប្សរាសហការជាមួយអ្នកជំនាញចម្រុះជាតិសាសន៍នៃសាកលវិទ្យាល័យសិង្ហបុរី ធ្វើកំណាយដើម្បីសិក្សាអំពីមន្ទីរពេទ្យបុរាណដែលឈ្មោះថា ប្រាសាទទន្លេស្ងួត នោះបានរយៈពេលជាង ១០ថ្ងៃមក។

លោក ខៀវ ចាន់ បញ្ជាក់ថា ការជីកដីរកឃើញបដិមាបុរាណចំនួន៥ នៅត្រង់ចំណុចផ្លូវដែលអ្នកភូមិតែងដើរចេញចូល គឺដោយសារតែអ្នកភូមិប្រាប់ថា ពេលមកដល់ត្រង់នោះ គឺហាក់ដូចជាមានអ្វីម្យ៉ាងចង់តែបង្កហេតុឲ្យគេមានគ្រោះថ្នាក់ ហើយថ្មីៗមានបុរសម្នាក់បានជិះម៉ូតូដួលនៅកន្លែងនោះ ដោយគ្រាន់តែជាន់ដុំថ្មតូចមួយផុសចេញមកពីក្នុងដី៖ «ពេលដែលឃើញថ្មបន្តិចផុសចេញហ្នឹង យើងមិនដឹងថាជាអ្វីទេ ប៉ុន្តែពេលដែលខ្ញុំកាយមើលទៅ ឃើញបំណែកថ្មមានឆ្លាក់ជាក្បាច់ស្រកានាគ ហើយយើងក៏ពិគ្រោះគ្នាជាមួយអ្នកជំនាញជីករណ្តៅតូចមួយ ដើម្បីយករូបទាំងនោះចេញ»។

អនុប្រធាននាយកដ្ឋានមជ្ឈមណ្ឌលអន្តរជាតិ និងតម្កល់ឯកសារអង្គរ លោក អ៊ឹម សុខរិទ្ធី ឲ្យដឹងថា រូបទាំង៥ ដែលគេប្រទះឃើញនោះមានទម្រង់ផ្សេងៗពីគ្នា ដោយខ្លះទំនងជារូបទេពប្រណម្យ ប៉ុន្តែរូបមួយក្នុងចំណោមនោះ លោកអះអាងថាគឺជាព្រះពុទ្ធស្តេចថ្នាំ ដែលភាសាសំស្រ្កឹតហៅថា ភៃសជ្យគុរុ៖ «ដែលយើងសម្គាល់ថានេះជាព្រះពុទ្ធស្តេចថ្នាំ ដោយសារមានសមាធិ ដាក់ព្រះហស្ត

ឆ្វេងនៅលើព្រះហស្តស្តាំ ហើយបាតដៃនៃព្រះហស្តស្តាំមានរូបភាពផ្លែឈើ ដែលខ្មែរហៅថាផ្លែស្រម៉»។

រូបទាំង៥ ដែលគេទើបជីកដីរកឃើញនេះ បានបែកបាក់ជាច្រើនផ្នែកទៅហើយ។

អ្នកស្រាវជ្រាវបុរាណវិទ្យាមកពីប្រទេសសិង្ហបុរី លោក លឹម ចេនស៊ាន (Lim Chen Sian) បានសម្តែងអារម្មណ៍រំភើប ដោយលោកបញ្ជាក់ថា នេះជាលើកទី៥ ហើយដែលលោកមកធ្វើកំណាយនៅកម្ពុជា មិនដែលបានជួបរូបបដិមាដូច្នេះទេ។

ចំណែកអ្នកបុរាណវិទ្យាអាមេរិកាំង លោក ដេវីដ ខាលយ៍ (David Kyle) មានប្រសាសន៍ថា នេះជាលើកដំបូងហើយដែលលោកបានឃើញរូបបដិមាបុរាណ បន្ទាប់ពីរូបលោកបានចូលរួមធ្វើកំណាយនៅកម្ពុជា ជាច្រើនលើកមកហើយ។

កាលពីថ្ងៃទី២៩ ខែកក្កដា ក្រុមអ្នកធ្វើកំណាយចម្រុះជាតិសាសន៍នេះ បានរកឃើញរូបបដិមាទ្វារបាលទម្ងន់ប្រហែល ៣០០គីឡូក្រាម នៅប្រាសាទទន្លេស្ងួត នោះម្តងមកហើយ៕

**៥.គេហទំព័រ** Fresh news

## *កំណាយស្រាវជ្រាវនៅអតីតមន្ទីរពេទ្យបុរាណ នាប្រាសាទទន្លេស្ងួត រកឃើញព្រះបដិមា «ភៃសជ្យគុរុ» ដែលជាព្រះពុទ្ធស្តេចថ្នាំ*

Fresh news 08/08/2017



(សៀមរាប)៖ ក្នុងគម្រោងស្រាវជ្រាវ ស្តីពីមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យា នៃអាជ្ញាធរជាតិ អប្សរា និងមហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍ នៃប្រទេសសិង្ហបុរី បន្តប្រទះឃើញព្រះពុទ្ធបដិមាច្រើនបំណែកទៀត ក្នុងនោះមានព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថា ជាព្រះពោធិ៍សត្វដែលមានព្រះនាមហៅថា«ភៃសជ្យគុរុ»ដែលមានន័យថាព្រះពុទ្ធគ្រូស្តេចថ្នាំនៅសម័យបុរាណ។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយ នៅព្រឹកថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧នេះ មុនបន្តជីក និងលើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្តៅកំណាយទី៤នៅផ្នែកខាងកើតនៃប្រាសាទទន្លស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ផងដែរ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រ នៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះ ត្រូវបានជីកឃើញនៅល្ងាចថ្ងៃទី៦ខែសីហា ហើយតាមការពិនិត្យទម្រង់ នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។

បើតាម លោក អ៊ឹម សុខរិទ្ធី ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្តេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ត ឬដៃមានដុំមូលមួយ រាងដូច សាជី។ លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧។

នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅ ប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ ទៅ ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្តៅកំណាយនៅផ្នែកខាងកើតប្រាសាទ។ ក្នុងរណ្តៅនេះ ដដែល ក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ។ បើតាមការបញ្ជាក់របស់អ្នកជំនាញ បំណែក ទាំង២នោះ មានបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំនោះ។

សូមបញ្ជាក់ថា គម្រោងសិក្សាស្រាវជ្រាវ នៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្តើមពី ថ្ងៃទី២៨ ខែកក្កដា ដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧៕

**៦.គេហទំព័រ កម្ពុជាថ្មី**

***កំណាយស្រាវជ្រាវ នៅអតីតមន្ទីរពេទ្យ បុរាណនាប្រាសាទទន្លេ ស្ងួតរកឃើញព្រះបដិមា«ភៃសជ្យគុរុ» ដែលជាព្រះពុទ្ធស្តេចថ្នាំ***

គ្រឿន វេត 09/08/2017 09:27am(កម្ពុជាថ្មី)



សៀមរាប៖ ក្នុងគម្រោងស្រាវជ្រាវ ស្តីពីមន្ទីរពេទ្យក្នុង រាជ្យ ព្រះបាទជ័យវរ្ម័នទី៧ ក្រុមអ្នកស្រាវជ្រាវបុរាណ វិទ្យានៃអាជ្ញាធរជាតិអប្សរា និងមហាវិទ្យាល័យបច្ចេក វិទ្យា និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេស សិង្ហបុរី បន្តប្រទះឃើញព្រះពុទ្ធបដិមាច្រើនបំណែក ទៀត ក្នុងនោះមានព្រះពុទ្ធបដិមាមួយអង្គ ដែលគេ ស្គាល់ថា ជាព្រះពោធិ៍សត្វ ដែលមានព្រះនាមហៅថា «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូ ស្តេចថ្នាំនៅសម័យបុរាណ។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ សីហា ឆ្នាំ២០១៨ មុនបន្តជីកនិង លើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅ រណ្តៅកំណាយទី៤នៅផ្នែកខាងកើតនៃប្រាសាទទន្លេស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យ វរ្ម័នទី៧ផងដែរ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរ ជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះ

ពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦សីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។

តាមលោក អ៊ឹម សុខរិទ្ធី ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្ដេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ដ ឬដៃមានដុំមូលមួយ រាងដូច សាជី។ លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧។

គួរឲ្យដឹងថា នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្ដៅកំណាយនៅផ្នែកខាងកើត ប្រាសាទ។ ក្នុងរណ្ដៅនេះដដែល ក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ។ តាមការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមានបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំនោះ។

សូមបញ្ជាក់ដែរថា គម្រោងសិក្សាស្រាវជ្រាវនៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្ដើមពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី១១ សីហា ឆ្នាំ២០១៧៕

**៧.គេហទំព័រ កោះសន្តិភាព**

### *រកឃើញព្រះបដិមា «ភៃសជ្យគុរុ» ដែលជាព្រះពុទ្ធស្ដេចថ្នាំ*

ដោយ ៖ ច័ន្ទ រស្មី ថ្ងៃអង្គារ ទី៨ ខែសីហា ឆ្នាំ២០១៧ ម៉ោង ២០:២៧ (កោះសន្តិភាព)



ខេត្តសៀមរាប៖ ក្នុងគម្រោងស្រាវជ្រាវស្ដីពីមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា និងមហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍ នៃប្រទេសសិង្ហបុរី បន្តប្រទះឃើញព្រះពុទ្ធបដិមាច្រើនបំណែកទៀត ក្នុងនោះ មានព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថា ជាព្រះពោធិសត្វ ដែលមានព្រះនាមហៅថា «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្ដេចថ្នាំនៅសម័យបុរាណ។ ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧ មុននឹងបន្តជីក និងលើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។

បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្ដៅកំណាយទី៤ នៅផ្នែកខាងកើតនៃប្រាសាទទន្លេស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧ផងដែរ។ លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦ សីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។ លោក អ៊ឹម សុខរិទ្ធី បានបន្តថា ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយ

ដែលគេដឹងថា ជាព្រះពុទ្ធស្តេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ថ មានដុំមូលមួយ រាងដូចសាជី។

លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។ គួរបញ្ជាក់ឱ្យដឹងថា នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្តៅកំណាយនៅផ្នែកខាងកើត ប្រាសាទ។ ក្នុងរណ្តៅនេះដដែល ក៏បានប្រទះឃើញបំណែក២ផ្សេងទៀតដែរ តាមការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមានបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំនោះ។ សូមបញ្ជាក់ផងដែរថា គម្រោងសិក្សាស្រាវជ្រាវនៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្តើមពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី ១១ សីហា ឆ្នាំ២០១៧៕

**៨.គេហទំព័រ** VOD

### *អាជ្ញាធររកឃើញបដិមាព្រះពុទ្ធស្តេចថ្នាំក្នុងរាជ្យស្តេចជ័យវរ្ម័នទី៧*

ដោយ លោក ពៅ មេត្តា | ថ្ងៃពុធ ទី៩ ខែសីហា ឆ្នាំ២០១៧ ១២:៤៥pm (VOD)




ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា និងមហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេ យ៍នៃប្រទេសសិង្ហបុរី រកឃើញព្រះពុទ្ធបដិមាច្រើនបំណែកជាព្រះពោធិ៍សត្វ ដែលមានព្រះនាមហៅថា «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្តេចថ្នាំនៅសម័យបុរាណ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦ ខែសីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។ នេះបើតាមការគេហទំព័រអាជ្ញាធរជាតិអប្សរា។

តាមលោក អ៊ឹម សុខរិទ្ធី ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្តេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ថ ឬដៃមានដុំមូលមួយ រាងដូច សាជី។

លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧ មុនបន្តជីកនិងលើកព្រះពុទ្ធរូបចេញពីកន្លែងកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្តៅកំណាយទី៤នៅផ្នែកខាងកើតនៃប្រាសាទទន្លេស្ងួត ដែលជាមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ផងដែរ៕

**៩.គេហទំព័រ ខ្លីៗ**

*រកឃើញបដិមា ព្រះពុទ្ធស្តេចថ្នាំ នៅអតីតមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧*

08/08/2017 ម៉ោង 16:01 (ខ្លីៗ)




ក្រុមអ្នកស្រាវជ្រាវបុរាណវិទ្យា បានប្រទះឃើញព្រះពុទ្ធបដិមាមួយអង្គ ដែលគេស្គាល់ថា ជាព្រះពោធិ៍សត្វព្រះនាម «ភៃសជ្យគុរុ» ដែលមានន័យថា ព្រះពុទ្ធគ្រូស្តេចថ្នាំ នៅសម័យបុរាណ នៅក្នុងការធ្វើកំណាយស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត ដែលជាអតីតមន្ទីរពេទ្យបុរាណក្នុងរាជព្រះបាទជ័យវរ្ម័នទី៧។

ក្រុមអ្នកស្រាវជ្រាវ បានរៀបចំពិធីសាសនាមួយនៅព្រឹកថ្ងៃទី៨ ខែសីហានេះ មុនបន្តជីក និងលើកព្រះពុទ្ធរូបចេញពីកន្លែង កំណាយ។

លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកប្រឹក្សាផ្នែកវិទ្យាសាស្ត្រនៃគម្រោងស្រាវជ្រាវនេះ បានឲ្យដឹងថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦ ខែសីហា ហើយតាមការពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗពីគ្នា។

លោកបន្តថា ក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺមានបដិមាមួយដែលគេដឹងថា ជាព្រះពុទ្ធស្តេចថ្នាំ ដោយពិនិត្យលើទម្រង់រូប ដែលនៅលើព្រះហស្ត ឬដៃមានដុំមូលមួយ រាងដូចសាជី។ លោកបន្ថែមថា រូបទាំងនោះតែងតម្កល់នៅគ្រប់មន្ទីរពេទ្យនៅក្នុងរាជ្យ ព្រះបាទជ័យវរ្ម័នទី៧។

គួរឲ្យដឹងថា នេះជាបដិមាទី២ហើយ ដែលអ្នកបុរាណវិទ្យាបានប្រទះឃើញនៅក្នុងគម្រោងស្រាវជ្រាវនៅប្រាសាទទន្លេស្ងួត។ បដិមាដ៏ធំមួយអង្គមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ ០,៥៨ម៉ែត្រ បានរកឃើញនៅរណ្តៅកំណាយនៅផ្នែកខាងកើតប្រាសាទ៕

**១០.គេហទំព័រ ថ្មីៗ**

*កំណាយស្រាវជ្រាវនៅទន្លេស្ងួតបន្តឃើញបដិមាសំខាន់របស់ប្រាសាទ*

08, Aug 2017 , 12:15 pm ដោយ: អ៊ីុសា រ៉ហានី(ថ្មីៗ)




សៀមរាបៈ អ្នកបុរាណវិទ្យានៃគម្រោងសិក្សារួមគ្នាអំពីមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ បានបន្តរកឃើញព្រះពុទ្ធរូបច្រើន បំណែកនៅការដ្ឋានកំណាយ។ បដិមាដែលខ្លះជាព្រះពុទ្ធប្រក់នាគ ត្រូវបានរកឃើញនៅរណ្តៅកំណាយទី៤នៅផ្នែកខាងកើតនៃប្រាសាទទន្លស្ងួត ដោយអ្នកបុរាណវិទ្យានៃ

អាជ្ញាធរជាតិអប្សរា និងអ្នកបុរាណវិទ្យានៃមហាវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី។
លោក អ៊ឹម សុខរិទ្ធី អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិ ស្រាវជ្រាវ និងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរា បានឲ្យដឹងថា នេះជារណ្តៅទី២ហើយ ដែលបានប្រទះឃើញព្រះពុទ្ធរូប ក្រោមគម្រោងស្រាវជ្រាវពីមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។ លោកបន្តថា បំណែកព្រះពុទ្ធរូបទាំងនោះត្រូវបានជីកឃើញនៅល្ងាចថ្ងៃ៦ សីហា និងបន្តជីកបន្ថែមរហូតធ្វើឲ្យគេបានឃើញ និងពិនិត្យទម្រង់នៃបំណែករូបទាំងនោះ ថាជាបំណែករូបផ្សេងៗគ្នា។
អ្នកបុរាណវិទ្យាបានរៀបចំពិធីសាសនាមួយមុនបន្តជីកនិងលើករូបបដិមាចេញមកក្រៅ ដែលរៀបចំនៅការដ្ឋាន នៅព្រឹកថ្ងៃទី៨ សីហា។
តាមការបញ្ជាក់របស់លោក អ៊ឹម សុខរិទ្ធី អ្វីដែលពិសេសក្នុងចំណោមព្រះពុទ្ធរូបទាំងនោះ គឺពុទ្ធបដិមាមួយអង្គ ដែលតាមការសង្កេត គឺជាព្រះពុទ្ធរូបដ៏សំខាន់ដែលតម្កល់នៅក្នុងប្រាសាទទន្លេស្ងួត និងជាមន្ទីរពេទ្យផងនោះ។ ព្រះពុទ្ធរូបនោះ គឺនៅលើព្រះហស្តមានដុំមូលមួយជាចម្លាក់នៅពីក្រៅរាងមូល មើលទំនងជារាងដូចសាជីតូចល្មមនៅលើបាតព្រះហស្ត ជាលក្ខណៈព្រះពុទ្ធមួយអង្គនៅក្នុងព្រះពុទ្ធសាសនាមហាយាន ដែលគេតែងហៅថា «ព្រះពុទ្ធភៃសជ្យគុរុ» ឬមានន័យថា គ្រូស្តេចថ្នាំ ហើយរូបទាំងនោះតែងមាននៅតាមប្រាសាទរបស់មន្ទីរពេទ្យ ឬរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងថ្នាំសង្កូវ។
ពុទ្ធបដិមាដែលរកឃើញនៅពេលនេះ គឺស្ថិតនៅលើផ្លូវលំមួយដែលអ្នកស្រុកតែងធ្វើដំណើរចេញចូលជារៀងរាល់ថ្ងៃ និងមានសភាពរាក់។ យ៉ាងណា លោក អ៊ឹម សុខរិទ្ធី អះអាងថា ជារូបដែលកប់យូរលង់មកហើយ។ ព្រោះថាស្រទាប់ដី និងកំណាកដីដែលកកជាប់នឹងសាច់ថ្មនៃព្រះពុទ្ធរូប គឺមានសភាពរឹងខុសពីធម្មតា មិនដូចដីថ្មីដែលទន់ជ្រាយនោះឡើយ។ តាមការប៉ាន់ស្មានរបស់អ្នកបុរាណវិទ្យា រូបនេះអាចត្រូវគេចោលនៅកណ្តាលវាល ហើយត្រូវបានកកដោយធម្មជាតិ។
លោក ខៀវ ច័ន្ទ អ្នកស្រាវជ្រាវក្នុងគម្រោងកំណាយនៅប្រាសាទទន្លេស្ងួតបានឲ្យដឹងថា នៅទីតាំងដែលប្រទះឃើញបំណែកពុទ្ធបដិមានោះ ជាផ្លូវចេញចូលរបស់អ្នកស្រុក ហើយតាមដំណាលរបស់អ្នកស្រុក ថាពួកគាត់តែងមានអភូតហេតុដូចចង់ឲ្យដួលម៉ូតូ រាល់ពេលធ្វើដំណើរកាត់ទីនោះ។ លោក ច័ន្ទ បន្ថែមថា នៅថ្ងៃដែលឃើញរូបនោះ មានអ្នកស្រុកម្នាក់ដួលម៉ូតូ ដោយប៉ះនឹងថ្មមួយ ហើយលោកក៏ទៅកាយមើលឃើញមានព្រះពុទ្ធប្រក់នាគ។
ក្នុងគម្រោងនេះដែរ កាលពីថ្ងៃទី២៨ កក្កដា ក្នុងកំណាយរណ្តៅខាងកើត បានប្រទះចម្លាក់បដិមាដែលមានកម្ពស់រហូតដល់ទៅ ១,៩០ម៉ែត្រ និងស្មាទទឹងរហូតដល់ទៅ ០,៥៨ម៉ែត្រ។ បន្ទាប់មករំលងមួយសប្តាហ៍ បំណែកពុទ្ធរូបតូចៗចំនួន២ទៀត ត្រូវបានរកឃើញនៅរណ្តៅដដែល ដែលតាម

ការបញ្ជាក់របស់អ្នកជំនាញ បំណែកទាំង២នោះមួយបំណែកជាកំភួនជើង នៃរូបបដិមាដ៏ធំ ដែលអ្នកស្រាវជ្រាវអះអាងថាជាទ្វារបាលនោះ។
គួរឲ្យដឹងផងដែរថា គម្រោងសិក្សាស្រាវជ្រាវនៃមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ចាប់ផ្ដើមពីថ្ងៃទី២៨ កក្កដា ដល់ថ្ងៃទី១១ សីហា ឆ្នាំ២០១៧។ អ្នកស្រាវជ្រាវបានបើករណ្ដៅកំណាយលើទីតាំងផ្សេង២គ្នា ដោយផ្នែកខាងកើតចំនួន៤កន្លែង និងខាងលិច ២កន្លែង នៃបរិវេណប្រាសាទទន្លេស្ងួត។ តាមប្រធានគម្រោងនៃអាជ្ញាធរជាតិអប្សរា ការធ្វើកំណាយខាងកើត គឺដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងផ្លូវបុរាណ ដែលចេញពីជើងក្រុងអង្គរធំឆ្ពោះទៅផ្នែកខាងជើង និងទំនាក់ទំនងផ្លូវនឹងមន្ទីរពេទ្យ និងខាងលិច ដើម្បីដឹងពីការផលិតថ្នាំ និងការព្យាបាលរោគជាដើម៕